**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីសម្រេចកែសម្រួលលើកទី៣
# លើឯកសារអាជ្ញាប័ណ្ណ លេខ ០២៣ ឯអ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣
# សម្រាប់លោក ឃុន សំបូរ
# អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងឯកសារអាជ្ញាប័ណ្ណរួមលេខ ០២៣ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោក ឃុន សំបូរ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣
- យោងលិខិតស្នើសុំពង្រីកតំបន់ចែកចាយរបស់លោក ឃុន សំបូរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៧
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៧ ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៧
- យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី១១០ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧

## សម្រេច

### ប្រការ១

កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០២៣ឯអ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលបានផ្តល់ជូនលោក **ឃុន សំបូរ** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅទីប្រជុំជនផ្សារព្រៃទទឹង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដោយអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនី ដែលមានស្រាប់ (មានបង្ហាញក្នុងផែនទី ភ្ជាប់លេខ 023LD - map - Khun Sambo - Rev3 - 2007 ) ។

### ប្រការ២

ឧបសម្ព័ន្ធទី១ចាស់ នៃឯកសារអាជ្ញាប័ណ្ណលេខ ០២៣ ឯអ ត្រូវជំនួសដោយ ឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។

### ប្រការ៣

សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០២៣ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃអាជ្ញាប័ណ្ណ លេខ ០២៣ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាម ទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០២៣ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ០២៣ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មី ស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី១
## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## លើកទី ១១០ នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧

១- តំបន់អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺនៅទីប្រជុំជនផ្សារព្រៃទទឹង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ " ផែនទីកំណត់ព្រំ ប្រទល់លេខ 023LD - map - Khun Sambo - Rev3 - 2007 " ដែលភ្ជាប់មកជាមួយ ។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំពង្រីកតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់ របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកតំបន់ចែកចាយនោះ ។

## ឧបសម្ព័ន្ធទី២
## មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

### ក រោងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ

១- រោងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ ជារោងធ្វើអំពីថ្ម ដំបូលសង្កសី ទំហំ ៨ x ១២ ម៉ែត្រ ស្ថិតនៅភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុក ព្រៃឈរ ខេត្តកំពង់ចាម ។

### ខ លក្ខណៈទូទៅនៃម៉ាស៊ីន

១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០៤គ្រឿង ដែលមានអានុភាព តម្លើងសរុប 464 kVA :

-ម៉ាក HINO អានុភាពតំឡើង 250 kVA

-ម៉ាក MITSUBISHI អានុភាពតំឡើង 2 x 75 kVA

-ម៉ាក ISUZU អានុភាពតំឡើង 64 kVA

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងម៉ាស៊ូត ។

៣- ធុងប្រេងចំណុះ ១០០០០លីត្រ

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។